NSW GOVERNMENT Education Public Schools

What does it mean if my child is suspended or expelled from school?

តើវាមានន័យដូចម្តេច បើកូនរបស់ខ្ញុំត្រូវបានព្យួរ ឬបណ្តេញចេញពីសាលារៀន?

តើការព្យួរមានន័យដូចម្តេច?

ការព្យួរមានន័យថា កូនរបស់លោកអ្នកមិនអាចទៅសាលារៀន ឬចូលទៅក្នុងបរិវេណសាលារៀនរយៈពេលច្រើនថ្ងៃ។ លោកអ្នកគឺជាអ្នកទទួលខុសត្រូវចំពោះការគ្រប់គ្រងកូនរបស់លោកអ្នក នៅពេលដែលពួកគេត្រូវបានព្យួរ។ ការព្យួរមានពីរប្រភេទ៖ ការព្យួររយៈពេលខ្លី (រហូតដល់៤ថ្ងៃសិក្សា) និងការព្យួររយៈពេលវែង (រហូតដល់២០ថ្ងៃសិក្សា)។ មានតែនាយកសាលាទេដែលអាចសម្រេច ថាតើសិស្សណាម្នាក់ត្រូវបានព្យួរឬអត់ និងរយៈពេលប៉ុន្មាន។

តើគោលបំណងនៃការព្យួរគឺដើម្បីអ្វី?

ការរក្សាស្តង់ដារខ្ពស់នៃអាកប្បកិរិយារបស់សិស្ស គឺជាផ្នែកមួយនៃការផ្តល់ការបង្រៀន និងការសិក្សាប្រកបដោយគុណភាពដល់សិស្សទាំងអស់។ ការព្យួរគឺជាវិធីមួយក្នុងការឆ្លើយតបទៅនឹងអាកប្បកិរិយាដែលមិនអាចទទួលយកបានក្នុងលក្ខណៈធ្ងន់ធ្ងរ។ វាមិនមែនជាការដាក់ទណ្ឌកម្មទេ។

ក្នុងករណីភាគច្រើន ការព្យួរត្រូវបានធ្វើឡើងចំពោះការប្រព្រឹត្តខុសធ្ងន់ធ្ងរ ឬក្នុងករណីសកម្មភាព ឬការគាំទ្រផ្សេងទៀតមិនបាននាំឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា។

ការព្យួរ ទុកឱ្យមានពេលវេលាសម្រាប់សាលារៀនរៀបចំផែនការជាមួយឪពុកម្តាយសិស្ស និងអ្នកថែទាំ អំពីវិធីល្អបំផុតដើម្បីគាំទ្រដល់សិស្សនាពេលអនាគត។

តើនឹងមានអ្វីកើតឡើង ប្រសិនបើកូនរបស់ខ្ញុំត្រូវបានព្យួរ?

លោកអ្នកនឹងទទួលបានលិខិតមួយច្បាប់ពីនាយកសាលា ដែលប្រាប់លោកអ្នកពីមូលហេតុអ្វីបានជាកូនរបស់លោកអ្នកត្រូវបានព្យួរ ហើយការព្យួរនេះនឹងមានរយៈពេលយូរប៉ុណ្ណា។ លោកអ្នកក៏នឹងទទួលបានច្បាប់ចម្លងស្តីពីនីតិវិធីព្យួររបស់ក្រសួងផងដែរ។

ក្នុងករណីមានការព្យួររយៈពេលវែង សាលារៀននឹងផ្តល់ជូនកម្មវិធីការងារមួយសម្រាប់កូនរបស់លោកអ្នកសម្រាប់ធ្វើនៅផ្ទះ។

លោកអ្នកនឹងត្រូវបានស្នើសុំឱ្យមកសាលារៀន ដើម្បីដោះស្រាយបញ្ហានៃការព្យួរនេះឱ្យបានឆាប់ តាមដែលអាចធ្វើទៅបាន។ លោកអ្នកអាចនាំអ្នកគាំទ្រម្នាក់មកចូលរួមក្នុងកិច្ចប្រជុំបាន ប្រសិនបើលោកអ្នកចង់។

តើការបណ្តេញចេញមានន័យដូចម្តេច?

ការបណ្តេញចេញមានន័យថា កូនរបស់លោកអ្នកមិនអាចចូលរៀននៅសាលារៀនណាមួយបានទៀតទេ។ មានហេតុផលពីរយ៉ាងចំពោះការបណ្តេញចេញនេះ៖ ការប្រព្រឹត្តខុសធ្ងន់ធ្ងររបស់សិស្សក្នុងវ័យណាមួយ ឬការចូលរួមដោយមិនពេញចិត្តរបស់សិស្សដែលមានអាយុលើសពី១៧ឆ្នាំ។

តើខ្ញុំអាចប្តឹងតវ៉ាបានឬទេ?

លោកអ្នកអាចដាក់ពាក្យបណ្តឹងតវ៉ាបាន ប្រសិនបើលោកអ្នកគិតថាការព្យួរ ឬការបណ្តេញចេញនេះមិនយុត្តិធម៌ ឬគិតថាមិនបានអនុវត្តតាមនីតិវិធីទាំងនោះ។ បុគ្គលិកសាលា និងការិយាល័យសេវាកម្មសាលាក្នុងតំបន់អាចផ្តល់ព័ត៌មានអំពីដំណើរការនីតិវិធីបណ្តឹងតវ៉ាបាន។

ស្វែងរកទម្រង់បែបបទបណ្តឹងតវ៉ាជាភាសាផ្សេងទៀត នៅត្រង់អ៊ីបុសៃ https://education.nsw.gov.au/public-schools/going-to-a-public-school/translated-documents/suspension-expulsion-appeals

កូនរបស់លោកអ្នកមិនអាចទៅសាលារៀនបានទេ ក្នុងអំឡុងពេលព្យួរ បើទោះបីជាលោកអ្នកដាក់ពាក្យបណ្តឹងតវ៉ាក៏ដោយ។

តើខ្ញុំអាចទទួលបានច្បាប់ចម្លងនៃនីតិវិធីព្យួរទាំងនេះនៅកន្លែងណា?

ពីសាលារៀនរបស់លោកអ្នក ឬនៅតាមអ៊ីបុសៃនេះ៖ https://education.nsw.gov.au/policy-library/associated-documents/suspol_07.pdf

តើនរណាអាចជួយបាន?

សួរព័ត៌មាននៅការិយាល័យសាលា ដើម្បីសុំធ្វើការណាត់ជួបជាមួយនឹងនាយកសាលា ឬសុំលេខទូរស័ព្ទរបស់ការិយាល័យសេវាកម្មសាលាក្នុងតំបន់។

សេវាអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា ដើម្បីជួយលោកអ្នកទាក់ទងមកសាលារៀន ឬការិយាល័យសេវាកម្មសាលាក្នុងតំបន់ សូមទូរស័ព្ទទៅសេវាអ្នកបកប្រែភាសាតាមទូរស័ព្ទ លេខ 131 450 ហើយស្នើសុំអ្នកបកប្រែជាភាសារបស់លោកអ្នក។ អ្នកប្រតិបត្តិករនឹងភ្ជាប់អ្នកបកប្រែភាសាទៅនឹងទូរស័ព្ទដើម្បីជួយបកប្រែការសន្ទនារបស់លោកអ្នក។ គេនឹងពុំគិតថ្លៃសេវាកម្មនេះពីលោកអ្នកឡើយ។